# សន្និសីទជាតិ
# ស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
# មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត

ថ្ងៃទី២១-២២ខែកុម្ភៈ ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលកោះពេជ្រ

## បទអន្តរាគមន៍
## ស្តីពី
## សារៈសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

- **ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា គ.ជ.អ.ប**
- **ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ**
- **ឯកឧត្តម ព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ ជាប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការ និងអគ្គនាយកតាមក្រសួង ស្ថាប័នពាក់ព័ន្ធ**
- **ឯកឧត្តម លោកជំទាវ លោកស្រី លោក ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
- **ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាដៃគូអភិវឌ្ឍន៍**
- **លោក លោកស្រី ប្រធានមន្ទីរពាក់ព័ន្ធរាជធានី ខេត្ត**
- **លោកស្រី លោក មេឃុំ ចៅសង្កាត់ ជាទីគោរពរាប់អាន**

ក្នុងនាមក្រសួងកិច្ចការនារី ខ្ញុំមានសេចក្តីសោមនស្សរីករាយ និងមានកិត្តិយសយ៉ាងក្រៃលែង ដែលត្រូវបានអញ្ជើញឱ្យចូលរួមធ្វើបទអន្តរាគមន៍ ស្តីពីសារៈសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នៅក្នុងសន្និសីទជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការៈ មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត ។

ខ្ញុំសូមសម្តែងនូវការកោតសសើរដោយស្មោះចំពោះលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការលើកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ទាំងនៅក្នុងក្របខណ្ឌគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងក្នុងក្របខណ្ឌនៃការអនុវត្ត ដើម្បីធានាដល់ការលើកកម្ពស់ការចូលរួមរបស់ស្ត្រី បុរស និងក្រុមបាត់បង់ឱកាស និងងាយរងគ្រោះ នៅគ្រប់វិស័យ និងគ្រប់កម្រិត ។

សន្និសីទជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលរៀបចំនាថ្ងៃនេះ គឺជា

សន្និសីទដ៏មានសារៈសំខាន់ក្នុងការឆ្លុះបញ្ចាំងនូវបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅថ្ងៃអនាគត សម្រាប់អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យកាន់តែមានប្រសិទ្ធភាព។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ អនុញ្ញាតឱ្យនាងខ្ញុំជម្រាបជូនពីសារៈសំខាន់ នៃការលើកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដូចតទៅ៖

**ឯកឧត្តម លោកជំទាវ លោកស្រី លោក**

រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់យ៉ាងច្បាស់នូវសារៈសំខាន់ នៃការលើកកម្ពស់សមភាពយេនឌ័រ ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ ទី២ និងទី៣ ដែលបានចាត់ទុកថា **ស្ត្រី គឺជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចជាតិ។** ក្នុងន័យនេះ រាជរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្ពស់ ក្នុងការអនុវត្តនូវគោលនយោបាយសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ទាំងស្រុងនូវសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរស សមភាពចំពោះមុខច្បាប់ ការលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងការធានានូវសិទ្ធិក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌នៃប្រទេសជាតិ។

ឆ្លើយតបការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្រសួងកិច្ចការនារី សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ដឹកនាំ និងក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប បានបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងផែនការ កម្មវិធី និងលិខិតបទដ្ឋានគតិយុត្តនានា ដែលដាក់ចេញដោយ គ.ជ.អ.ប ។

**ការបញ្ជ្រាបយេនឌ័រ៖** សំដៅលើការផ្តោតការយកចិត្តទុកដាក់ ក្នុងការកាត់បន្ថយគម្លាតរវាងបុរស និងស្ត្រីដែលកើតឡើងតាមរយៈការរំពឹងទុកនិងផ្នត់គំនិតរបស់គ្រួសារ និងសង្គម។

**បរិយាប័ន្ន៖** សំដៅលើការផ្តោតការដាក់បញ្ចូល និងគិតគូរដល់គ្រប់ក្រុមគោលដៅទាំងអស់ក្នុងសង្គម ។

**សមធម៌សង្គម៖** សំដៅលើវិធានការនានា ដើម្បីឈានទៅកាត់បន្ថយគម្លាត នៃការទទួលបានអត្ថប្រយោជន៍ នៅក្នុងសង្គម ឬជួយដល់ក្រុមដែលពុំសូវមានឱកាស ឬងាយរងគ្រោះ ឱ្យទទួលបានផលពីកិច្ចអភិវឌ្ឍ ។

ការបញ្ជ្រាបយេនឌ័រ ក្នុងបរិបទសមធម៌សង្គម និងបរិយាប័ន្ន គឺជាការរំលឹក ឬជំរុញការគិតគូរ និងឆ្លើយតប ដោយមិនត្រឹមតែផ្តោតការយកចិត្តទុកដាក់លើស្ត្រី និងបុរសទូទៅនោះទេ ប៉ុន្តែត្រូវរកឲ្យឃើញ និងដោះស្រាយនូវបញ្ហា កង្វល់ និងតម្រូវការជាក់លាក់របស់ស្ត្រី និងបុរស ទូទៅផង និងស្ត្រី

បុរស កុមារា កុមារី ដែលស្ថិតក្រុមមនុស្សគ្រប់ប្រភេទ មានដូចជាក្រុមពិការ ក្រុមជនជាតិដើមភាគតិច ក្រុមស្ត្រីក្រីក្រ ។ល។ ដើម្បីឈានទៅសម្រេចបាននូវសមភាពរបស់ជនគ្រប់រូប ទាំងបុរស ទាំងស្ត្រី ក្នុងការ ចូលរួម ការទទួលផល ការគ្រប់គ្រង និងធ្វើសេចក្តីសម្រេចពីសេវាកម្ម និងកិច្ចអភិវឌ្ឍន៍ ។

**ឯកឧត្តម លោកជំទាវ លោកស្រី លោក**

និយាយជារួម ទាំងយុទ្ធសាស្ត្រ ក្នុងការបញ្ជ្រាបយេនឌ័រ ទាំងបរិយាប័ន្ននិងសមធម៌សង្គម គឺមានគោលដៅ ដើម្បីធានាថា **យើងទាំងអស់គ្នា មិនទុកអ្នកណាម្នាក់ឱ្យនៅឯកកោរ ។**

ចំណុចនេះ គឺជាហេតុផលចម្បងនៃដាក់ចេញនិងអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ បានកំណត់ និងមានបំណងឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ សម្រេចនូវលទ្ធផលជាក់លាក់ ក្នុងការលើកស្ទួយគុណភាព នៃជីវិតរស់នៅប្រជាពលរដ្ឋមូលដ្ឋាន **ដោយចាប់ផ្តើមពីជនក្រីក្រ និងជនងាយរងគ្រោះ ។**

ជាក់ស្តែង**ក្របខណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ** ដែលបានអនុម័តនៅឆ្នាំ២០០៥ បានកំណត់នៅគោលការណ៍សំខាន់ៗ សម្រាប់ផ្តល់ការណែនាំតម្រង់ទិសដល់ការធ្វើកំណែទម្រង់នៅថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍គ្រឹះនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលធានាថា ប្រជាពលរដ្ឋ ជាពិសេស ស្ត្រី ជនពិការ ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ អាចចូលរួមនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនោះ។

**ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា** ដែលបានដាក់ចេញ នៅឆ្នាំ២០០១ បានកំណត់នូវបញ្ញត្តិនានាដែលតម្រូវឱ្យមានការរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធកសាងផែនការ និងកិច្ចដំណើរការធ្វើការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី សំដៅដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់ខ្លួន ឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយសមធម៌ ជាពិសេសឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ និងតម្រូវឱ្យមានគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ (គ.ក.ន.ក) អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ នៅតាមឃុំ សង្កាត់ និងការតម្រូវឱ្យមានតំណាងស្ត្រីពីភូមិនីមួយៗ ធ្វើជាសមាជិក នៃគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ គឺជាយន្តការដ៏សំខាន់ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចនៅថ្នាក់ឃុំ សង្កាត់ ។ យន្តការនេះអាចធានាបានថា សម្លេងនិងតម្រូវការនានារបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ ត្រូវបានឆ្លើយតបក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពោល គឺពួកគេត្រូវបានផ្តល់ឱកាស និងលើកទឹកចិត្តឱ្យចូលរួម និងទទួលផលប្រយោជន៍ ប្រកបដោយសមធម៌ពីការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ ។

**ច្បាប់ ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា** ក៏បានចែងនូវបញ្ញត្តិពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវធានាដល់ការលើកកម្ពស់សមភាពយេនឌ័រទាំងនៅក្នុងការតែងតាំង ការគ្រប់

គ្រងបុគ្គលិក ការរៀបចំផែនការអភិវឌ្ឍន៍ ការរៀបចំថវិកា ព្រមទាំងការបង្កើតនូវយន្តការ និងនីតិវិធីនានា ដើម្បីធានាថា បញ្ហានិងតម្រូវការរបស់ស្ត្រី កុមារ ជនពិការ និងក្រុមជនងាយរងគ្រោះ ត្រូវបានផ្តោតការយកចិត្តទុកដាក់ ក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។ ការជំរុញឱ្យមានការតែងតាំងមន្ត្រីជាស្ត្រីក្នុងមុខតំណែងថ្នាក់ដឹកនាំ (អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) និងការរៀបចំបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ (គ.ក.ស.ក) ដែលស្ថិតក្រោមការដឹកនាំរបស់សមាជិកក្រុមប្រឹក្សាជាស្ត្រី គឺជាយន្តការដ៏មានសារៈសំខាន់ ក្នុងការជំរុញ និងលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេច នៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ យន្តការនេះជំរុញឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគិតពិចារណាអំពីបញ្ហា និងតម្រូវការពាក់ព័ន្ធនឹងស្ត្រី យុវវ័យ កុមារ ជនពិការ និងក្រុមជនងាយរងគ្រោះផ្សេងទៀត ក្នុងការធ្វើសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។

**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ (២០១០-២០១៩)** បានដាក់ចេញដោយរាជរដ្ឋាភិបាលសម្រាប់ធ្វើជាផែនទីបង្ហាញផ្លូវ ក្នុងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ បានផ្តោតការយកចិត្តកាន់តែខ្លាំងលើការបញ្ជ្រាបយេនឌ័រ ការបង្កើនភាពអង់អាចដល់ស្ត្រី និងការជំរុញការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។ កម្មវិធីជាតិបានគូសបញ្ជាក់យ៉ាងច្បាស់ថា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រកបដោយនិរន្តភាព លុះត្រាតែមានសមភាពយេនឌ័រ និងយុត្តិធម៌សង្គមជាមូលដ្ឋាន ដែលក្នុងនោះទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលស្គាល់សេចក្តីត្រូវការខុសគ្នារវាងស្ត្រី បុរស និងធ្វើកិច្ចការយ៉ាងសកម្មដើម្បីដោះស្រាយបញ្ហាវិសមភាពយេនឌ័រ ដែលមាននៅក្នុងមូលដ្ឋាន និងសហគមន៍ផ្ទាល់របស់ខ្លួន ដើម្បីធានាបញ្ហាយេនឌ័រត្រូវបានដោះស្រាយ ចាំបាច់ត្រូវផ្តោតការបញ្ជ្រាបយេនឌ័រលក្ខណៈអន្តរវិស័យដោយបញ្ចូលគោលការណ៍សមភាព និងសមធម៌យេនឌ័រ។ ក្នុងន័យនេះ កម្មវិធីជាតិ បានកំណត់នូវយុទ្ធសាស្ត្រដ៏ទូលំទូលាយសម្រាប់ការបញ្ជ្រាបយេឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ទាំងក្នុងកម្រិតបុគ្គល និងកម្រិតស្ថាប័ន នៅតាមសមាសធាតុកម្មវិធីទាំង៥ ដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្ត ក្នុងនោះ រួមមាន៖ ១)ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ២)ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣)ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ៤)ការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង៥)ការរៀបចំស្ថាប័នគាំទ្រកិច្ចដំណើរការកំណែទម្រង់ ។

**ផែនការអនុវត្តបីឆ្នាំដំបូងនៃកម្មវិធីជាតិ "ផអ៣ទី១"** ដែលបានអនុវត្តពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៤ បានកំណត់នូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីយ៉ាងជាក់លាក់ ដើម្បីធានាថា **បញ្ហាយេនឌ័រត្រូវបញ្ជ្រាបក្នុងប្រព័ន្ធគ្រប់គ្រង កិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកា នីតិវិធីអនុវត្តការងារ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់**

**ក្រោមជាតិ។ ផអ៣ទី១** បានប្រគល់ការទទួលខុសត្រូវលើស្ថាប័នអនុវត្តទាំងអស់ត្រូវធានាថា ការងារយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី ត្រូវបានបញ្ជ្រាបទៅក្នុងដំណើរការនៃការរៀបចំ និងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ខ្លួន ។ ក្រសួងកិច្ចការនារី ត្រូវបានផ្តល់តួនាទីជាស្ថាប័នប្រឹក្សាយោបល់ជាយុទ្ធសាស្ត្រ ផ្តល់ការគាំទ្រ និងធានាឱ្យមានភាពប្រទាក់ក្រឡាគ្នារវាងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៃផអ៣ ជាមួយនឹងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនានារបស់រាជរដ្ឋាភិបាល។

**ផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទីពីរនៃកម្មវិធីជាតិ «ផអ៣ទី២»** ដែលអនុម័តដោយ គ.ជ.អ.ប សម្រាប់អនុវត្តពីឆ្នាំ២០១៥-២០១៧ ក៏បានបន្តផ្តល់អាទិភាពទៅលើការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផអ៣ទី២ បានកំណត់នូវលទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ និងសូចនាករជាក់លាក់ពាក់ព័ន្ធនឹងការបង្កើនចំនួន មន្ត្រីជាស្ត្រីក្នុងមុខតំណែងថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ សូចនាករជាក់លាក់មួយចំនួនទាំងនោះ រួមមានការបង្កើនចំនួនមន្ត្រីជាស្ត្រីឱ្យបានយ៉ាងតិច១៦% ក្នុងមុខតំណែងជានាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាពនៃសាលារាជធានី ខេត្ត និងយ៉ាងតិច២២% ក្នុងមុខតំណែងជានាយក នាយករងរដ្ឋបាល និងប្រធាន អនុប្រធានការិយាល័យ អង្គភាពនៃសាលាក្រុង ស្រុក ខណ្ឌ ។ ផអ៣ទី២ ក៏បានកំណត់នូវយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់មន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយតម្រូវឱ្យមន្ត្រីថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវចូលរួមវគ្គការបណ្តុះបណ្តាលជាកាតព្វកិច្ចជារៀងរាល់ឆ្នាំ អំពីយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ក្នុងគោលបំណងជួយឱ្យថ្នាក់ដឹកនាំ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានគំនិតផ្តួចផ្តើម ក្នុងការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន ដែលធានាដល់ការលើកកម្ពស់ការឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី កុមារ និងក្រុមងាយរងគ្រោះនានា នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ លើសពីនេះ ផអ៣ទី២ ក៏បានកំណត់នូវវិធានការចាំបាច់នានា ក្នុងការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមនៅតាមលទ្ធផលរំពឹងទុកនីមួយៗ ដើម្បីធានានូវការផ្តល់សិទ្ធិដល់ក្រុមផ្សេងៗ ជាពិសេសក្រុមជនងាយរងគ្រោះនិងក្រុមជនក្រីក្រឱ្យទទួលបានឱកាសសមស្រប ក្នុងការចូលរួម និងទទួលផលប្រយោជន៍ដោយមិនរើសអើងពីការផ្តល់សេវា ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងពីល័ក្ខខ័ណ្ឌនានានៃការធ្វើសេចក្តីសម្រេចផ្នែកនយោបាយនៅតាមមូលដ្ឋាននីមួយៗ។

**ផែនការអនុវត្តបីឆ្នាំ ដំណាក់កាលទីបីនៃកម្មវិធីជាតិ «ផអ៣ទី៣»** សម្រាប់អនុវត្តពីឆ្នាំ២០១៨-២០២០ បានបន្តផ្តល់អាទិភាពលើការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម ត្រូវការបញ្ជ្រាបក្នុងលទ្ធផលរំពឹងទុកពាក់ព័ន្ធនានានៃសមាសភាគទាំង៥។ នៅក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិដោះស្រាយ និងលើកកម្ពស់សុខុមាលភាពរបស់ក្រុមជនងាយរងគ្រោះនានា តាមរយៈអនុវត្តផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រី ក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពង្រីកការអនុវត្តនូវគោលការណ៍នានា នៃផែនការយុទ្ធសាស្ត្រ ក្នុងការបង្កើនចំនួនស្ត្រី ក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវគ្គបណ្តុះបណ្តាលកាតព្វកិច្ច បញ្ជ្រាបការលើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងរាល់គោលនយោបាយ កម្មវិធី ការអភិវឌ្ឍសមត្ថភាព ការផ្តល់សេវា ពង្រីកវិសាលភាពនៃការធ្វើសាវនកម្មយេនឌ័រ ដោយដាក់បញ្ចូលនូវបញ្ហាបរិយាប័ន្ន និងសមធម៌សង្គម រៀបចំកម្មវិធីជាក់

លាក់នានា ដែលមានការកំណត់អំពីការចំណាយច្បាស់លាស់ ដើម្បីគាំទ្រដល់ក្រុមយុវជន ជនពិការ ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ រៀបចំបណ្តាញ និងបែបផែននានានៃការត្រួតពិនិត្យតាមដាន ដើម្បីផ្លាស់ប្តូរមេរៀន និងបទពិសោធន៍ ពង្រឹងស្ថាប័នសំខាន់ៗ ដូចជាក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងស្ថាប័ន គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្រ្តីនិងកុមាររបស់ក្រុមប្រឹក្សា នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ឯកឧត្តម លោកជំទាវ លោកស្រី លោក**

**ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម** មិនមែនត្រឹមតែបានកំណត់ឡើង តាមរយៈការដាក់ចេញ និងអនុវត្តតាមគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋាននានានោះទេ ប៉ុន្តែវាគឺជាការវិនិយោគដ៏មានតម្លៃ និងប្រកបដោយគ្រប់ជ្រុងជ្រោយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ។ មានន័យថា ធនធានមនុស្ស និងគ្រប់សមាសភាពនៃកិច្ចអភិវឌ្ឍន៍ទាំងអស់ ត្រូវបានយកមកគិតគូរ យកចិត្តទុកដាក់ និងឆ្លើយតប ព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ត្រឡប់មកវិញកាន់តែប្រសើរជាងមុន សម្រាប់គ្រួសារ ស្ថាប័ន និងសហគមន៍របស់ខ្លួន ។

ជារួម ក្រោមក្របខ័ណ្ឌ នៃការអនុវត្តកម្មវិធីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចបានគូសបញ្ជាក់ខាងលើ យើងទទួលបាននូវលទ្ធផលវិជ្ជមានគួរជាទីមោទនៈ។

សេចក្តីសម្រេច ស្តីពីការដាក់ឲ្យប្រើប្រាស់ឯកសារបច្ចេកទេស ស្តីពីការលើកម្ពស់សមធម៌សង្គម និងបរិយាប័ន្ននៅថ្នាក់ក្រោមជាតិ នៅខែកញ្ញា ឆ្នាំ២០១៦។

ប្រធាន និងមន្ត្រីក្រុមការងារបច្ចេកទេសវិមជ្ឈការនិងវិសហមជ្ឈការក្រសួងស្ថាប័នពាក់ព័ន្ធបានបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្តីពីយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ដើម្បីបង្កើនការយល់ដឹង និងបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមនៅក្នុង វិស័យនីមួយៗ។

ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរកិច្ចការនារី ទីប្រឹក្សាផអ៣ និងមន្ត្រីមណ្ឌលអភិវឌ្ឍធនធានមនុស្សចំនួន២៥រាជធានី ខេត្ត បានក្លាយជាគ្រូបង្គោលស្តីពីការលើកកម្ពស់សមធម៌សង្គមនិងបរិយាប័ន្ន និងបានបណ្តុះបណ្តាលបន្តដល់គណៈអភិបាល ក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ផែនការយុទ្ធសាស្រ្ត ស្តីពី "ការបង្កើនចំនួនស្រ្តី ក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" ត្រូវបានអនុម័តដោយ **សម្តេចក្រឡា ហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធាន គ.ជ.អ.ប** នាខែមេសា ឆ្នាំ២០១៧ ដែលបានកំណត់ ៖

- *២០% នៃនាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាព នៃសាលារាជធានី ខេត្ត ជាស្រ្តី ។*
- *២៥% នៃនាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានអង្គភាព នៃសាលាក្រុង ស្រុក ខណ្ឌ ជាស្រ្តី ។*

វគ្គជាកាតព្វកិច្ច ស្តីពី «**ការលើកកម្ពស់សមធម៌ និងបរិយាប័ន្នសង្គម**» ក្នុងភាពជាអ្នកដឹកនាំដល់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ចំនួន១៥ ក្នុងឆ្នាំ២០១៧ និងបន្ត១០ខេត្តទៀត ក្នុងឆ្នាំ២០១៨ មានគោលបំណងដើម្បីសម្របសម្រួល និងជំរុញឱ្យថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់ក្នុងការវិភាជន៍ ធនធាន និងអនុវត្តសកម្មភាពក្នុងការលើកកម្ពស់យេនឌ័រ សមធម៌ និងបរិយាប័ន្នសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាស្ត្រី ក៏មានការកើនឡើងផងដែរ ដែលក្នុងនោះនៅថ្នាក់រាជធានី ខេត្ត មានការកើនឡើងពី៩,៨៩% ក្នុងអាណត្តិទី១ទៅ១៣,២៣%នៅអាណត្តិទី២ និងនៅថ្នាក់ក្រុង ស្រុក ខណ្ឌមានការកើនឡើងពី១២,៦៨%នៅអាណត្តិទី១ ទៅ១៣,៨៥%នៅអាណត្តិទី២ ។ អភិបាលជាស្ត្រីចំនួន០១រូប អភិបាលរងជាស្ត្រីយ៉ាងតិច០១រូប ត្រូវបានតែងតាំងនៅតាមរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ដែលរហូតដល់បច្ចុប្បនេះមានស្ត្រីជាអភិបាលរងរាជធានី ខេត្តចំនួន២៦រូប អភិបាលក្រុង ស្រុកចំនួន៧រូប និងអភិបាលរងក្រុង ស្រុក ខណ្ឌចំនួន១៩៤រូប។ មន្ត្រីរាជការជាស្ត្រីនៅថ្នាក់ជាតិ និងក្រោមជាតិ មាន៣២%ឆ្នាំ២០០៧ កើនឡើងដល់៤១% ឆ្នាំ២០១៧ ។

រួមជាមួយនឹងកិច្ចការជាច្រើនទៀត ដែលបានអនុវត្តផ្ទាល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅចូលរួមចំណែកក្នុងការអភិវឌ្ឍន៍មូលដ្ឋាន។

ឆ្លៀត ក្នុងឱកាសនេះ ក្នុងនាមក្រសួងកិច្ចការនារី នាងខ្ញុំសូមស្តែងនូវក្តីសោមនស្សរីករាយ និងសូមថ្លែងនូវអំណរគុណនូវកិច្ចសហការភាពជាដៃគូរបស់លេខាធិការដ្ឋានគ.ជ.អ.ប ការគាំទ្រ និងផ្តល់ឱកាសពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំគ្រប់កម្រិត និងការចូលរួមទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ក្នុងការធានាដល់ការសម្រេចបាននូវចំណុចដៅនានាពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌ តាមការកំណត់ក្នុងផអ៣ទី៣នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

ជាមួយគ្នានេះ ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប នឹងបន្តពង្រឹងកិច្ចសហការក្នុងផ្តល់ការសម្របសម្រួល និងគាំទ្រដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រ និងវិធានការនានា ដើម្បីធានាដល់ការសម្រេចបានតាមចំណុចដៅពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ដែលបានកំណត់ក្នុងក្របខណ្ឌគតិយុត្ត និងក្របខណ្ឌកម្មវិធីសម្រាប់ការអនុវត្ត។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ដែលបានយកចិត្តទុកដាក់ស្តាប់ ។

សូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលបានសុខភាពល្អបរិបូរណ៍ និងជោគជ័យគ្រប់ភារកិច្ចការងារ។

សូមអរគុណ!!!